# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ភ្នំពេញ-ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦៖ នៅសាលប្រជុំរដ្ឋាករទឹកក្រុងភ្នំពេញ មានរៀបចំពិធីចុះហត្ថលេខាលើ ប្រកាសរួមស្តីពី កិច្ចសហប្រតិបត្តិការសម្រួលដល់ការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជា រវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម កម្ពុជា និងការិយាល័យប្រកាសនីយបត្រតក្កកម្មនៃប្រទេសជប៉ុន ។ ហត្ថលេខី នៃពិធីនេះភាគីកម្ពុជា ចុះហត្ថលេខាដោយឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ភាគីជប៉ុនចុះហត្ថលេខាដោយលោក HITOSHI ITO ស្នងការប្រកាសនីបត្រនៃប្រទេសជប៉ុន ។




*រៀបចំដោយ៖ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

មានប្រសាសន៍នាឱកាសនោះ **ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** បានសម្តែងនូវមោទនភាពចំពោះសមិទ្ធិផលថ្ងៃនេះ ដែលបានសហការជាមួយដៃគូជប៉ុនមួយទៀត បន្ទាប់ពីការងារដូចគ្នានេះយើងបានចុះហត្ថលេខារួចហើយជាមួយដៃគូសឹង្ហបុរី កាលពីដើមឆ្នាំ ២០១៥ កន្លងទៅ ។ ជាមួយគ្នានេះយើងក៏កំពុងរៀបចំដំណើរការសហការជាមួយ ដៃគូសហគមន៍អឺរ៉ុបផងដែរ ។ អត្ថប្រយោជន៍ គឺធ្វើឲ្យសម្រុងគ្នានូវនីតិវិធីនិងបែបបទ ការសហការគ្នាក្នុងការទទួលពាក្យសុំពិនិត្យការទទួលស្គាល់ការផ្តល់ប្រកាសនីបត្រតក្កកម្ម និងការចុះបញ្ជីគំនូរឧស្សាហកម្ម ទៅវិញទៅមក ដែលនឹងជួយដល់ការពន្លឿននៃលំហូរពាណិជ្ជកម្ម និងការវិនិយោគផ្ទាល់ពីបរទេស ព្រោះគេមានទំនុកចិត្តលើប្រព័ន្ធច្បាប់ និងសមត្ថភាពដែលអាចការពារដល់កម្មសិទ្ធិឧស្សាហកម្ម ដែលគេដាក់ទុនវិនិយោគនៅកម្ពុជា ។ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានថ្លែងអំណរគុណដល់ភាគីជប៉ុនដែលបានលើកឡើងពន្យល់ពីអត្ថប្រយោជន៍ និងលក្ខខណ្ឌនៃការចូលជាសមាជិកភាព នៃសន្ធិសញ្ញា ប្រកាសនីយបត្រតក្កកម្ម (PCT) ព្រមទាំងបង្ហាញនូវជំហរប្តេជ្ញាចិត្ត ជួយដល់ការបណ្តុះបណ្តាលដល់មន្ត្រីកម្ពុជាទៀតផង ។ ជាការឆ្លើយតប ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបញ្ជាក់ថា ក្រសួងឧស្សហកម្ម និងសិប្បកម្ម នឹងរៀបចំដាក់ពាក្យចូលជាសមាជិកសន្ធិសញ្ញា (PCT) នៅពេលខាងមុខដ៏ខ្លីនេះ និងស្នើឲ្យភាគីជប៉ុនបណ្តុះបណ្តាលដល់មន្ត្រីក្រសួងនូវជំនាញមួយចំនួនដូចជាៈ ផ្នែកអនុវត្តសទ្ធិសញ្ញា (PCT) ការទទួលបានព័ត៌មាន និងការសរសេររបាយការណ៍ផ្ញើជូនជាដើម ។









*រៀបចំដោយ៖ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ















*រៀបចំដោយ៖ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន*